# ១១- រឿង ចចក

## បទភាគគតិ

នេះបទកាកា គតិចរចា ចែងចងរឿងរាយ
តាមពាក្យពីព្រេង តតែងនិយាយ ដំណើរអភិប្រាយ
ពីសត្វចចក ។

យោនយកកំណើត កំណត់កាលកើត ពីងពួនជ្រៀតជ្រក
ក្នុងរូងថ្មភ្នំ ផារធំសៀតសឹក សព្វថ្ងៃចចក
ស្វែងរកភោជនា ។

ប្របន្ទេរអូរស្ទឹង ត្រពាំងបួបឹង ជ្រោះជ្រោយបព្វតា
លុះយប់ផ្កាល់ផ្កាប់ ចុះចាប់មច្ឆា តែងបរិភោគ្គា
សព្វថ្ងៃប្រក្រតី ។

រូបទាបក្រញីញ បាទបួនតឿទេញ កាចខ្ចូចអប្រិយ
តែងដើរលាកលះ ស្វែងស្វះរកស៊ី ព្រួយនឿយឥន្ទ្រិយ
ស្គាំងស្គមអាត្មា ។

ពីកាលក្មេងនៅ មេស្លាប់ចោលទៅ នៅតែនឹងបា
នាំដើររកស៊ី ប្របទីជលសា លុះធំកាលណា
បាស្លាប់បង់បាត់ ។

ចចកនោះនៅ ទល់ទុក្ខក្តាត់ក្តៅ ក្នុងថ្ងៃមប្រមាត់
ឥតមេឥតបា កំព្រាព្រាកព្រាត់ ស្ងប់ស្ងួតស្ងៀមស្ងាត់
ត្រមោចម្នាក់ឯង ។

ចចកគន់គិត រំពឹងក្នុងចិត្ត រិងរិតចំបែង
ដើររកភោជនា ភោគ្គាកណ្តែង កណ្តោចឯកឯង
ឥតមានគ្នីគ្នា ។

វេលាចូលដេក ក្នុងទីដំណេក ត្រូវភ្លៀងរងា
ខ្យល់បក់ស្ងប់ស្ងួត ថ្ងៃមស្ងួតគ្រាំគ្រា ក្រៀមក្រំកំព្រា
កំប្រោនពេកពន់ ។

ចចករិះគិត បានឃើញគំនិត មួយនោះជាលន់
ថាអញត្រូវរក ត្រូវយកប្រពន្ធ ទើបបាននឹងស្រន់
នឹងស្រាលទុក្ខា ។

គ្រាន់ជាគូថៅ ស្នេហានែបនៅ ក្នុងរូងបព្វតា
ចចកគិតថ្នោះ ក្រោកស្មោះយាត្រា ត្រាច់ក្នុងព្រឹក្សា
ស្រង្ងួតស្រងាត់ ។

ដើរត្រេចតែឯង កណ្តោចកណ្តែង កំព្រាព្រាកព្រាត់
ត្រមោចត្រមង់ នៅក្នុងព្រៃស្ងាត់ ប្រទះហ្វូងសត្វ
គោតគោមហិង្សា ។

ទន្សោងទន្សាយ ដំរីប្រើសទ្រាយ ឈ្លូសក្តាន់សូករា
រមាសរមាំង ខ្ទីខ្លាំងខ្លោងខ្លា ដើររកភោគ្គា
សឹងសត្វយង់ឃ្នង ។

ចចកឃើញសត្វ សាហាវរង្គាត់ ច្រើនក្រៃកន្លង
កៀងកាល់គួវា ខ្សៀវខ្វាររឹងកង គិតភ័យកន្លង
ស្ទើរបាត់ស្មារតី ។

ខំដើររំលង ចៀសសត្វយង់ឃ្នង បានដល់នទី
ស្ទឹងមួយថ្លាជ្រះ ត្រចះយល់ដី ចចកចាប់ត្រី
ចំអែតកាយា ។

ហើយហែលឆ្លាស់ឆ្លង ស៊ឹងនោះរំលង ដល់ត្រើយគង្គា
ត្រេចក្នុងរបោះ ចន្លោះអធ្វា មានរូងគុហា
ជិតជើងគិរី ។

ចចកចូលជិត ប្រុងប្រាណមូលមិត្ត មៀងមើលរកញី
ឱនចុះងើបងើត ចំអើតមើលទី ក្សិណនោះមានញី
ចចកមួយណា ។

នៅក្នុងរូបថ្ម សិលាដ៏ល្អ ក្បាលសមកាយា
ចចកឈ្មោលគិត ក្នុងចិត្តថៃថា គួរអញសួរសារ
បន្តិចទើបបាន ។

ទើបឈ្មោលហារក ថាប្អូនពន្លក មិត្តមុំកល្យាណ
នៅក្នុងរូបថ្ម ល្អះល្អថ្កើងថ្កាន សព្វថ្ងៃតើមាន
ប្តីជាគូគ្រង ។

ឬនៅឯកឯង ប្អូនអើយចូរថ្លែង ប្រាយប្រាប់បងផង
ឱ្យបងរសាយ ក្នុងកាយនេះហោង បើឥតគូគ្រង
បងសុំស្នេហា ។

ចចកញីស្តាប់ ងាកហើយថ្លែងប្រាប់ ថាអ្នកសោភា
ប្អូននៅសព្វថ្ងៃ អាស្រ័យគុហា មិនមាននរណា
ជាគូឡើយនៃ ។

កាលដើមមានមេ មានបាបំពេ ឱបក្រុងសព្វថ្ងៃ
ឥឡូវមេបា មរណាក្សិណក្ស័យ ប្អូននៅសព្វថ្ងៃ
កំព្រាពេកពន់ ។

ឈ្មោលឮដូច្នោះ ព្រឺព្រួចពុងពោះ ហឫទ័យទោរទន់
ទើបឆ្លើយតបថា ប្អូនភ្ងាស្ងួនតន់ ប្អូនអើយបងគន់
បងគិតអនិច្ចា ។

អាសូរប្អូនស្ងួន មាសមិត្រខ្លីមខ្លួន កំព្រាឯកា
ដូចកលខ្លួនបង សៅហ្មងចិន្តា សព្វថ្ងៃបងមហា
ព្រួយណាស់ប្អូនអើយ ។

ចចកញីស្តាប់ ពាក្យឈ្មោលថ្លែងប្រាប់ ឆ្លើយថាអ្នកអើយ
ប្អូនស្តាប់ពាក្យអ្នក ជៀងជាក់ទៅហើយ ក្នុងចិត្តឥតស្បើយ
កើតទុក្ខទៀតថ្មី ។

ប្អូនចង់សូមសួរ ហៅមហាមិនគួរ ត្បិតខ្លួនជាស្រី
អ្នកថាព្រួយចិត្ត ព្រោះគិតរឿងអ្វី ប្រុសប្រាជ្ញប្រិមប្រិយ
ប្រាយប្រាប់ប្អូនវ៉ា ។

ឈ្មោលថាមាសមិត្រ បងព្រួយព្រោះគិត ដល់គូស្នេហា
គ្មានគ្នាជាពីរ ចំណេរអនា គតបងហៅមហា
ថប់ណាស់មាសបង ។

ញីថាប្រុសអើយ កុំថប់អ្វីឡើយ ប្អូនធានារង
វិះរកជួយគិត តាមចិត្តអ្នកបង ត្រងតាមបំណង
ចិត្តអ្នកប្រាថ្នា ។

ឈ្មោលថាមាសមិត្រ បងប៉ងផ្ញើចិត្ត ផ្ញើដួងជីវ៉ា
នៅលើប្អូនស្ងួន សូមនួនមេត្តា បងមិនប្រាថ្នា
ដទៃពីពៅ ។

ញីឆ្លើយថាអ្នក ចិត្តចង់រួមរ័ក្ស មូលមួយលំនៅ
ផ្ញើដួងចិន្តា ស្នេហាតទៅ នឹងប្អូននេះក្ងូវ
ពេញមហាអរពេក ។

ប៉ុន្តែប្អូនយល់ ប្អូនគិតទៅដល់ ឆ្ងាយឆ្ងល់ចំឡែក
ឋានអ្នកឯនាយ សប្បាយអនេក មានញីយ៉ាងឯក
គូគួរស្នេហា ។

ម្តេចអ្នកមិនមាន ចិត្តចាប់ចង់បាន ជាគូជីវ៉ា
ហើយប្រែលាកលះ ស្វែងស្វះយាត្រា ក្នុងព្រៃអដ្វា
មកដល់ឋានអាយ ។

ឈ្មោលស្តាប់ឆ្លើយឆ្លាស់ ជាហៃប្អូនមាស មានរូបឆោមឆាយ
ឆោមឆើតទងវង ឋានបងឯនាយ មែនហើយសប្បាយ
ដូចពាក្យប្អូនថា ។

គឺមោះបងរក គូគាប់នឹងយក ជាតិជាពនិតា
នឹងផ្ញើចិត្តខ្លួន ដូចស្ងួននេះណា គ្មានសោះបងមហា
ថប់ពេកនាងអាយ ។

ហេតុនោះបងស្វះ បងស្វែងលាកលះ មកដល់ឋានអាយ
បងប៉ងផ្ញើខ្លួន លើនួនឆោមឆាយ ព្រួយនឿយអង្គកាយ
ម្តេចៗមិនគិត ។

លែងតែប្អូនស្រី មាសមានមេត្រី មេត្តាមូលមិត្ត
មូលមួយចិន្តា ស្នេហាជួបជិត ជួបចាប់ប្រព្រឹត្ត
ជាគូវាសនា ។

ញីស្តាប់ឆ្លើយឆ្លៀត ឆ្លើយឆ្លងវិញទៀត ថាប្រុសស្នេហា
ពាក្យព្រៅល្អល្អះ គួរសះសង្កា ល្បួងលោមចិន្តា
បានហើយបោះបង់ ។

ឈ្មោលឆ្លើយថាហៃ ប្អូនមាសថ្លើមថ្លៃ បណ្តូលសាច់ស
ង្សារសមសោភា កាយាវររង្ស វរវាសអស់អង្គ
អស់ឥតសង្ស័យ ។

បងមហាស្រឡាញ់ ប្អូនមាសឈ្ងុយឆ្ងាញ់ ចាប់ចិត្តអាល័យ
អាឡោះលើសលន់ ពេកពន់ក្រាស់ក្រៃ ពុំបានបងក្ស័យ
ជីវិតជាម្តង ។

ឈ្មោលថាតែម្លោះ ចូលជិតចំពោះ ផ្គមផ្គាប់ហើយហោង
ថើបថ្ពាល់ឮខ្សឹត ចំតិតឆ្អឹងខ្នង ថាហៃមាសបង
នាង ! កុំខេខឹង ។

បំណាច់បងមក រកប្អូនពន្លក ឆ្លងអូរឆ្លងស្ទឹង
មិនស្តាយជីវិត ព្រោះចិត្តរំពឹង ទុកប្អូនព្រលឹង
ជាដួងស្នេហា ។

ញីអៀនអន់អាក់ ឱនមុខទុកភ័ក្ត្រ ចូលចិត្តចិន្តា
សេពសុខក្សេមក្សាន្ត ក្នុងឋានគុហា ទើបឈ្មោលលោមថា
ព្រលឹងបងណា ។

បងចង់នាំពៅ ឱះឱពេញក្តៅ ក្នុងចិត្តចិន្តា
អញចង់តែអត់ សង្កត់ខ្យល់វ៉ា ឱ្យស្លាប់មរណា
កុំឱ្យវេទនា ។

ដល់គិតវែងទៅ ក្រែងកើតហ្មងសៅ កើតកេរ្តិ៍និន្ទា
ថាឱ្យចចក កំព្រកមោហា ក្សិណក្ស័យជន្មា
ព្រោះញីបញ្ឆោត ។

បើនឹងស្លាប់រស់ ឱ្យឮកេរ្តិ៍យស គេមានកំណោត
មានពាក្យសរសើរ ថាអើអញកោត ចចកនេះសោត
ពេញហៅហានក្លា ។

គិតហើយបោលទៅ ជិតទឹករណ្តៅ ថាយើនរណា
បង្អើតជាក្តៅ ហ្មងសៅចិន្តា ងើយមើលមេឃថា
យើងក្តៅព្រោះថ្ងៃ ។

អើអញជាតិនេះ លំបាកទាំងម្លេះ ព្រោះតឿទាបក្រៃ
កើតជាចចក កំព្រកចង្រៃ ជាតិក្រោយអញថ្ងៃ
អញសូមសច្ចា ។

ទោះបីកបកើត យោនយកកំណើត ជាតិណាភពណា
អញសូមសម្រេច សេចក្ដីប្រាថ្នា កើតជាសុរិយា
រុងរឿងរង្សី ។

កាលនោះមានយក្ស ប្រេតមួយសំណាក់ ឋិតឋានប្រក្រតី
នៅលើបព្វតា ទៀបនាវិថី យក្សព្ទសំដី
ចចកប្រាថ្នា ។

យក្សគិតថាអើ មហាលាភណាស់តើ នឹងបានភោជនា
ត្រកាលចំណី ល្អក្រៃថ្លៃថ្លា នឹងបរិភោគ្គា
នូវសាច់ចចក ។

គួរអញកាឡា ជាអង្គឥន្ទ្រា ប្រាប់វាឱ្យយក
សាច់ឈាមជាទាន នឹងបានវិះរក កំណើតបានមក
កើតជាសុរិយា ។

យក្សគិតដូច្នោះ កាឡាចំពោះ ជាអង្គឥន្ទ្រា
ហិចហោះច្រៀវច្រៃ លើផ្ទៃវេហាស៍ ហើយមានវាចា
សាកសួរមេត្រី ។

ថាហៃចចក អ្នកត្រេចដើរមក ពីណារកអ្វី
ចចកក្រឡេក ឈ្មៀងភ្នែករំពៃ ស្មានអង្គកោសីយ៍
ទើបទូលទៅថា ។

បពិត្រព្រះឥន្ទ្រា ទ្រើសនវិន្ទ ឥសួរសុជាតា
ខ្ញុំមកស្មានស្មោះ ចំពោះប្រាថ្នា រកចាប់មច្ឆា
នៅក្នុងជលធី ។

បើបានមច្ឆា ដូចបងប្រាថ្នា យកទៅឱ្យញី
ត្បិតមានផ្ទៃពោះ ចិត្តស្មោះចង់ស៊ី ត្រីក្នុងជលធី
ទើបឆ្ងាញ់ណាស់ណា ។

ហេតុនេះខ្ញុំមក រុករានវិះរក សមុទ្រមច្ឆា
ដើរបែកញើសហូរ ហត់ហេវណាស់ណា ញើសហូរក្តៅផ្សា
ព្រោះថ្ងៃចាំងចែង ។

សូរ្យសែងថ្លើងថ្កាន ទើបខ្ញុំប្រណិធាន ចំពោះខ្លួនឯង
ចង់បានរស្មី លើសអស់គេឯង ទើបខ្ញុំសម្ដែង
អធិដ្ឋានថា ។

បើខ្ញុំនឹងកើត យកជាតិកំណើត ក្រោយខ្ញុំប្រាថ្នា
តាំងចិត្តចង់បាន ដូចភ្នានចិន្ដា កើតជាសុរិយា
ប្រាកដដូចបំង ។

បពិត្រឥន្ទ្រា សូមស្ដេចមេត្តា ជួយខ្លួនខ្ញុំផង
ធ្វើម្ដេចនឹងបាន ដូចភ្នានបំណង ប្រេតយក្សឆ្លើយឆ្លង
ថាងាយណាស់ណា ។

បើចៅចង់បាន ដូចចិត្តចំណាន បំណងប្រាថ្នា
ចូរចៅផ្ដិលផ្ដាច់ សម្រេចជន្មា យកសាច់ឱ្យជា
ទានយក្សបិសាច ។

ហេតុអានិសង្ស ជួយជូនទ្រទ្រង់ កើតមានអំណាច
ជាសែងសុរិយ៍ រស្មីចិញ្ចាច ចិញ្ចែងត្រដាច
ដូចចិត្តប្រាថ្នា ។

ចចកស្ដាប់គិត ជឿជាក់ចូលចិត្ត ទើបទូលទៅថា
ខ្ញុំចង់ឱ្យទាន សាច់ប្រាណហើយណា ប្រេតយក្សឆ្លើយថា
សាធុពីរដង ។

ប្រេតយក្សថាម្ល៉ោះ និម្មិតចំពោះ បាំងបាត់ទៅហោង
ចចករត់ចេញ បោលខ្លាញ់ជាម្ដង គិតថាអញប៉ង
បានដូចសេចក្ដី ។

ចចកគិតច្នោះ បោលដល់ទឹកចុះ លុយលបចាប់ត្រី
លុះចាប់ត្រីបាន ដូចភ្នានសេចក្ដី ប្រាថ្នាពាំត្រី
ឱ្យញីភោគ្គា ។

ញីឃើញឈ្មោលដល់ បានត្រីខ្វាយខ្វល់ ទទួលមច្ឆា
បរិភោគផ្សាយផ្សព្វ ស្កល់ស្កប់ចិន្ដា ទើបឈ្មោលប្រាប់ថា
ហៃប្អូនពិសី ។

កាលបងទៅយក មច្ឆានាំមក ឱ្យប្អូនប្រិមប្រិយ
ហៅមហាព្រួយប្រាណ ពុំក្សាន្តណាស្រី ស្ទើរខានបានត្រី
មកផ្ញើប្អូនភ្ងា ។

ប្អូនអើយថ្ងៃក្ដៅ ជើងបងពងនៅ រអាមអង្គា
ក្ដៅដល់ក្នុងថ្លើម ដង្ហើមទយា ដល់ដួលច្រើនគ្រា
ស្ទើរវិលក្រោយខាន ។

បងខំបោលទៅ ប្អូនអើយរីងក្ដៅ រន្ធត់អង្គប្រាណ
បងបោលហើយគិត ក្នុងចិត្តថាស្មាន ប្រហែលទាហាន
ច្បាំងសឹកមួយសោះ ។

គេជះសំណាង សំណួមសូមសាង ពីមុនមកនោះ
បានជួបឥន្ទ្រា យាត្រាចំពោះ ហើយស្ដេចអនុគ្រោះ
ស្មោះស្មានមេត្រី ។

ប្រដៅទូន្មាន នាំជានិទាន ឱ្យដឹងសេចក្ដី
បុណ្យបាបត្រូវខុស ហើយហោះចេញខ្មី បងចេញចាកទី
រកចាប់មច្ឆា ។

ចចកប្រាប់ញី សុសសព្វសេចក្ដី គ្មានខ្វះត្រង់ណា
ហើយលោមថាប្អូន ខ្លីមខ្លួនស្នេហា អញបងចង់លា
ទៅក្ស័យជីវិត ។

យកសាច់ជាទាន ប្រាថ្នាឱ្យបាន ជាព្រះអាទិត្យ
តើប្អូននឹងថា ម្ដេចម្ដាមាសមិត្ត ញីស្ដាប់ហើយគិត
ធុញថៃថប់ថា ។

អ្នកមាសប្អូនអើយ ប្អូនថាម្ដេចឡើយ ចិត្តអ្នកប្រាថ្នា
មិនហ៊ានខាំងឃាត់ ឱ្យភ្លាត់សច្ចា ក្រែងកើតទោសា
ជាប់ជិតដល់ប្រាណ ។

គឺមោះប្អូននៅ ក្រោយអ្នកប្រុសទៅ បោះបង់ចោលឋាន
ប្អូនកើតទុក្ខព្រួត ពីរត្រួតពុំក្សាន្ត ទុក្ខមួយព្រោះមាន
ទម្ងន់ពេញពោះ ។

ទុក្ខមួយព្រោះព្រាត់ ព្រោះប្រាសសូន្យស្ងាត់ សូន្យស្ងៀមក្រៀមក្រោះ
ក្រៀមក្រំក្នុងចិត្ត ឆ្អែងឆ្អិតអាឡោះ អាល័យស្រណោះ
អ្នកប្រុសប្រាសទៅ ។

សព្វថ្ងៃរំពឹង អ្នកមាសព្រលឹង ស្មានថាអ្នកនៅ
នែបនិត្យឱរ៉ា ស្នេហាតទៅ ប្អូនឥតញាតិផៅ
សង្ឃឹមតែអ្នក ។

ជាគូស្នេហា ទុក្ខស្មើចិតា មាតារួមរក្ស
រួមរស់ស្នេហ៍ស្នង ប្អូនប៉ងទុកដាក់ ផ្ញើខ្លួនលើអ្នក
លុះអស់ជន្មា ។

ហេតុនោះប្អូនស្ទះ ប្អូនស្វែងលាកលះ ចោលទីគុហា
ជិតដោយតាមអ្នក វរល័ក្ខសោភា ម្តេចឡើយឃ្លាតឃ្លា
ពីទ្រូងប្អូនពៅ ។

ញីថាតែម្ល៉េះ ឱនមុខទុក្ខចុះ ឱរ៉ាឈ្មួលក្តៅ
ហាក់ដូចអគ្គី ឆេះពីពោះទៅ ទល់ទុក្ខហ្មងសៅ
ជោរជល់នេត្រា ។

ស្ងៀមស្ងួតស្ងាត់ស្ងប់ ពុំចេញសារសព្ទ សារសងវាចា
រីងក្តៅក្នុងថ្លើម ដង្ហើមឱរ៉ា ទើបឈ្មោលលោមថា
សំឡាញ់បងអើយ ។

កុំនាងអាឡោះ អាល័យសោកសោះ សោកសោតឥតត្រើយ
បើបងបានកើត កំណើតថ្មោះហើយ បងមិនគោះគើយ
ទីទៃចោលពៅ ។

សឹមបងមកយក ប្អូនស្ងួនពន្លក បីបមថ្នមទៅ
ដាក់លើពិមាន ទិព្វឋានផ្អិនផ្អោ មូលមួយលំនៅ
នៃបនិត្យស្នេហា ។

ចូរប្អូនស្រីស្រួល ស្រីស្រស់ទទួល អនុមោទនា
ព្រមព្រិះនិងបង ដូចប៉ងប្រាថ្នា កុំនាងរួញរា
បើកបងតាមចិត្ត ។

ញីស្តាប់ឈ្មោលថា ហាក់ធូរឱរ៉ា សោកាស្បើយស្បិត
បន្ទោទុក្ខស្រាល ស្រយាលក្នុងចិត្ត ទើបឆ្លើយប្រឌិត
ថាតាមចិន្តា ។

អ្នកនិងផ្តិលផ្តាច់ ជីវិតយកសាច់ ជាទានប្រាថ្នា
យោនយកកំណើត កើតជាសុរិយា ប្អូនសោតជ្រះថ្លា
សាធុនិងអ្នក ។

ដំណើរចចក មោហាកំព្រក ឈប់ស្លេះជៀងជាក់
នេះនឹងចាប់និង ទានពីប្រេតយក្ស ចិតឋានសំណាក់
នៅលើបព្វតា ។

យក្សនិម្មិតមក លបមើលចចក យក្សស្តាប់ឮថា
ចចកផ្តិលផ្តាច់ សម្រេចជន្មា យក្សអរហើយថា
បរមល ភពេក ។

ហើយយក្សនិម្មិត បញ្ចូលក្នុងចិត្ត ចចកឱ្យត្រេក
កាត់ចិត្តឱ្យទាន សាច់គ្មានអល់អែក ហើយប្រេតយក្សស្រែក
សាធុការា ។

ចចកឈ្មោលញី លុះឮសំដី ប្រេតយក្សឱ្យសា
ធុការដូច្នោះ ស្រួលស្រះចិន្តា លង់លុះសុរិយា
អ័ព្ទអស្តង្គត ។

នាំញីចូលដេក ក្នុងរូងដំណោក ដូចដើមកំណត់
និងថ្លែងឯព្រៃ ធំក្រៃប្រាកដ ប្របផ្ទេរសមុទ្រ
គាប់កាលនោះណា ។

មានយក្ខិណី ប្រេតប្រាសឥតប្តី នៅក្នុងព្រឹក្សា
យក្សត្រេចរកប្តី ឃ្លាតឱ្យាត្រា បានដល់បព្វតា
ដែលយក្សប្រុសនៅ ។

យក្សស្រីឃើញម្លប់ ត្រជាក់ចូលឈប់ បន្ទិចបាត់ក្តៅ
យក្សស្រីថាអញ ឃ្មាតខ្មាញ់ចេញក្រៅ ដើរហាលថ្ងៃក្តៅ
សៅហ្មងភក្ត្រា ។

យក្សស្រីគិតថ្មោះ ដើររកទឹកជ្រោះ ឆ្លុះមើលមុខា
ឃើញហើយផ្អៀងផ្អង ឈ្មៀងឈ្មងនេត្រា យក្សសើចហើយថា
នៅល្អដែរទេ ។

អញងូតទឹកលាប លាងក្អែលឆ្អេះឆ្អាប ឱ្យគ្រាន់ជាងគេ
ថាស្រេចយក្សស្រី ឃ្មាតខ្មីងាករេ រកជ្រោះងូតថៃ
ដុសសព្វកាយា ។

ហើយយក្សឡើងយក សំពត់បានមក ស្លៀកហើយយាត្រា
ដើរទៅហើយគិត ក្នុងចិត្តយក្សថា ចង់ច្រៀងសិនវ៉ា
ឱ្យបានស្បើយទុក្ខ ។

យក្សស្រីគិតថ្មោះ ចាប់ក្បិនចងចុះ រេក្បាលងើបមុខ
គន់មើលរូបរាង ដូចពាងព្រហាក់ ម្លោះខំញីកញ៉ក់
ញាំញើដើរលេង ។

រេរារែករាំ បាទាទន្ទាំ ទន្ទើទន្ទេង
អង្គុយភ្លាមចុះ ជើងគោះជាភ្លេង ទះដៃច្រៀងលេង
ងេកងោកសិរិសា ។

ក្រឡេកស្តាំឆ្វេង ស្តាប់ទៅសំឡេង ដូចហ៊ីងសោកា
គគ្រោតគគ្រាក់ រលាក់ញាក់ស្មា ព្ធដល់យក្សា
ប្រេតឋិតលើភ្នំ ។

យក្សថាសំឡេង នរណាច្រៀងលេង លាន់ឮរងំ
ថាហើយយក្សប្រុស ចរចុះជើងភ្នំ ហើយយក្សសំងំ
លបល្មួចមើលមៀង ។

មើលមិញស្គាល់ជាក់ ថាអះឱយក្ស ស្រីទេស្រែកច្រៀង
យក្សប្រុសចង់ស្និទ្ធ បៀរជិតបញ្ឆៀង ផ្ទឹមផ្ទាប់ផ្ទាល់ផ្ទៀង
សាកសួរទៅថា ។

នាងស្រីក្រមុំ រូបរាងឧត្តម នាងមកពីណា
យក្សស្រីថាខ្ញុំ ខិតខំយាត្រា ចេញពីព្រឹក្សា
ដើររកចំណី ។

យក្សប្រុសថាអើ លាភលន់លុះលើ បំណងសេចក្តី
ប្រាថ្នាអញបង ចងចង់មេត្រី និងនាងប្អូនស្រី
ជាគូស្នេហា ។

យក្សស្រីថាកុំ លេងស៊ុនពេកខំ ហៅម៉ែអញវ៉ា
យើងមិនជាស្រី អប្រិយទេណា យើងមានមេបា
ពូជពង្សគ្រាន់បើ ។

យក្សប្រុសថាឱ អញចង់តែរក ពុទ្ធោទេតើ
នរណាធ្វើអ្វី ប្អូនស្រីគ្រាន់បើ យក្សស្រីថាអើ
គ្មានធ្វើអ្វីទេ ។

ប៉ុន្តែមាក់ងាយ ហ៊ានហានិយាយ ស្រដីចង់ចែ
ខំលេងពាក្យជ្រៅ អញទៅប្រាប់ម៉ែ យក្សស្រីគិតកែ
ការកើរ្តិ៍ចិញ្ចៀង ។

ប្រុសថាប៉ែអញ ព្រោះបងស្រឡាញ់ ទើបបងហ៊ានលេង
បុរសស្ត្រី សេចក្តីច្នេះឯង មាសមិត្តមិនឆ្វេង
សង្ស័យសោះឬ ។

យក្សស្រីថាស្អប់ ពាក្យប្រុសប្រសប់ ស្រដីពាលលើ
ថ្មោងថ្មីស្រឡាញ់ អស់អញឥតស្មើ បានហើយធ្វេសធ្វើ
តើយតស់បោះបង់ ។

ឯយក្សប្រុសនោះ បានឮដូច្នោះ សោមនស្សអស់អង្គ
អរងកស្រួលសើច សំណើចចំណង់ ថាប្អូនវរវង្ស
កែវកុំសង្ស័យ ។

ចិត្តបងស្រឡាញ់ ពិតៗពេកពេញ ចិត្តជួបភិសសម័យ
បងផ្ញើរូបខ្លួន លើធ្នួនថ្លើមថ្លៃ លង់លុះក្សិណក្ស័យ
មរណ៍មួយមូលមិត្ត ។

ហើយយក្សប្រុសនោះ ចរចូលជិតចុះ កៀកករួតរឹត
ដៃដល់ថនា យូរយារទឹមផ្ទិត យក្សស្រីភាំងភិត
អៀនឱនភ័ក្ត្រា ។

ព្រឺព្រួញប្របប្រាណ រួមរស់ស្មោះស្មាន ជិតជើងបព្វតា
អស្ចារ្យកន្លង់ ត្រេចត្រង់ត្រឹបផ្កា រសាយបុប្ផា
កេសរវិករុះ ។

ព្យុះសង្ឃរា ពិរុណរំលា ស្រក់ស្រោចចម្រុះ
នាគរាជពេនពង់ ក្រួញអង្គត្រដុះ ឱនក្បាលលូនចុះ
ចូលរូងបព្វតា ។

ព្រួសពិសអង់អាច សំដែងអំណាច ឥតខ្លាចនរណា
ក្អែរពិសពោរពាស ទីទាសត្រៀបត្រា ពេញរូងបព្វតា
ហើយសម្ងំជ្រក ។

ស្លេះរឿងយក្សទុក ថ្លែងតទៅមុខ អំពីចចក
ដេកក្នុងគុហា ដូចពណ៌នាមក ភ្ញាក់ឡើងរិះរក
គិតក្នុងចិន្តា ។

បើអញដាស់ញី ប្រាយប្រាប់អំពី ដំណើរអញណា
ក្រែងញីឃាត់ប្រាណ រំខានអាត្មា នាំស្តុនយាត្រា
មិនដូចបំណង ។

គួរអញលបរត់ ចេញចាកប្រាកដ សោះកើតសៅហ្មង
ចចកគិតច្នោះ លបស្ទុះចេញហោង ដើរស្រូតរំលង
ដល់ជ្រុងបព្វតា ។

ឃើញយក្សិណី ប្រែប្រាណឥន្ទ្រិយ ជាខ្មោចមាយា
ភិតញ័រចំប្រប់ ស្វែងស្ងប់រោមា ចចកម្ទីម្នា
ឡើងលើថ្មដា ។

ផ្ទេចភ្នែកលោតចុះ ធ្លាក់ក្នុងបាតជ្រោះ បាក់កអាត្មា
ក្សិណក្ស័យជីវី យក្សស្រីនោះណា ឃើញហើយជ្រះថ្លា
ក្រោកឈរឡើងរាំ ។

នេះបទព្រហ្មគីតិ ពិតពិនិត្យពិន័យនាំ
សេចក្តីកែពាក្យពាំ ពាក្យពីកាលចចកនោះ ។
ក្សិណក្ស័យជីពជន្មា យក្សម្នីម្នាលោតចុះ
រើសខ្មោចចចកនោះ នាំប្រពន្ធបរិភោគ្គា ។
ស៊ីសាច់ហែកហុតឈាម ហូររហាមពេញមុខា
ឈាមស្រក់ទៅត្រង់ណា យក្សឱនលិទ្ធឥតមានសល់ ។
ឆ្អឹងឆ្អែងយក្សទំពា ត្រង់លលាក្បាលសំណល់
បរិភោគឆ្អែតស្កប់ស្កល់ នាំប្រពន្ធវិលឋានឋិត ។
រីឯខ្មោចចចក ស្លាប់ទៅយកជាតិដូចចិត្ត
កើតជាព្រះអាទិត្យ រុងរឿងរះត្រចះថ្លា ។

ទុំទែងចងប្រាលផ្កោ ភ្លឺសន្ធៅទាំងលោកា
ស័ក្តិសិទ្ធិរិទ្ធិចេស្តា បរិវារចោមសម្រាប់បុណ្យ ។
ហេតុផលចចកបាន សាច់ឱ្យទានមកពីមុន
ជួយជូនកើតដោយគុណ បុណ្យចិត្តកាត់ឥតសង្កា ។
សុរិយាចចកគិត អរក្នុងចិត្តឥតឧបមា
ថាឱក្តីប្រាថ្នា អង្គអញអើយឆាប់ផុតក្រៃ ។
ម្ល៉េះហើយគ្មាននរណា ផ្ទឹមចេស្តាមានតេជដៃ
រុងរឿងថ្កើងជោគជ័យ នៃអង្គអញពេញត្បៀវត្លា ។
វិន័យដំណើរនេះ នឹងឈប់ស្នេះពុំចរចា
ចចកសែងសុរិយា ខណ្ឌខានទុកពុំស្រដី ។
ទើបនឹងនិទានពី ចចកញីភ្ញាក់ឡើងថ្មី
ឈ្មោលបាត់អង្គីក្តី ញីរត់រកតក្កមា ។
ស្រង់ក្លិនរកតាមផ្លូវ ដល់ជ្រោះជ្រៅឃើញសិរសា
សំណល់យក្ខភោក្តា ញីប្រះប្រាណដួលសន្លប់ ។
ភាន់ភាំងតាំងស្មារតី អស់ឥន្ទ្រិយញីចំប្រប់
ដង្ហើមហួតប្រសប់ ប្រដេញខ្យល់សល់សែនទ្វី ។
ហើយហៀបហាក់នឹងក្ស័យ ក្សិណប្រល័យជន្មជីវី
សូន្យសុងស្លុងនៅទី ជ្រោះដែលឈ្មោលក្ស័យនោះណា ។
លុះបានដឹងស្មារតី ភ្ញាក់ឥន្ទ្រិយខ្ញួញទៅថា
ឱ្យអ្នកប្រុសស្នេហា ម្តេចអ្នកមកក្ស័យបង់បាត់ ។
ចាកចោលប្អូនរងា នៅកំព្រាស្ងៀមស្ងប់ស្ងាត់
និរាសប្រាសព្រាកព្រាត់ ផុតពីទ្រូងប្អូនទៅហើយ ។

តាំងពីថ្ងៃនេះទៅ សមប្អូននៅឯកាឱ្យ
កើតទុក្ខឥតសះស្បើយ ឥតល្ហែល្ហើយពីទុក្ខា ។
ដូចប្រុសៗវរមិត្ត មិត្តខ្លីមចិត្តឥតសង្កា
ប្អូនប៉ងផ្ញើរូបា ដួងជីវ៉ានឹងអ្នកថ្លៃ ។
ម្តេចអ្នកចោលប្អូនទៅ ឱ្យប្អូននៅកំព្រាក្រៃ
ឥតពឹងឥតអាស្រ័យ បោះបង់បាត់ស្ងាត់ទៅហោង ។
សូវក្ស័យជីវិតទៅ ជាជាងនៅកើតសៅហ្មង
ទល់ទុក្ខៗចម្បង រងលំបាកលុះអស់កាល ។
ធ្លាប់ផឹកធ្លាប់ភោក្តា ធ្លាប់ចរចាធ្លាប់ស្និទ្ធស្នាល
ធ្លាប់នែបធ្លាប់ត្រអាល ធ្លាប់រួមរស់រួមមណ្ឌល ។
ឥឡូវអ្នកប្រុសប្រាស ប្រាសនិរាសពិតពុំយល់
អ្នកអើយសមប្អូនទល់ ទុក្ខកណ្តែងកណ្តាលព្រៃ ។
តាំងខ្ញួញពីព្រលប់ លុះចួបចប់ចូលដល់ថ្ងៃ
រឿងរះច្បាស់ព្រឹក្សព្រៃ ព្រឹកព្រាងស្វាងសែងសុរិយា ។
ចចកឃើញថ្ងៃជាក់ ថាឱអ្នកប្រុសស្នេហា
អ្នកបានជាសុរិយា រុងរឿងរះត្រចះផ្កោ ។
អ្នកយកប្អូនទៅផង ស្និទ្ធស្នេហ៍ស្នងនែបនិត្យនៅ
លើឋានទិព្វសន្ធៅ សោះហ្មងសៅសែនទុក្ខា ។
ចចកញីខ្ញួញទៀត តឹងចង្អៀតក្នុងឱរ៉ា
ប្រះប្រាណសែនសោកា សែនអាឡោះអាល័យលន់ ។
ពីព្រឹកលុះដល់ត្រង់ សោកសូន្យសុងទល់ទុក្ខធ្ងន់
លុះថ្ងៃទេរទាបទន់ ទាបទៅទៀបចុងព្រឹក្សព្រៃ ។

ភ្លេចផឹកភ្លេចភោក្តា    អត់ភោជនាស្គមសង្វៃ
សន្ធឹកនឹកអាល័យ    ទៀងខ្ទួញដួលប្រះប្រាណ ។
ថាឱព្រះសុរិយា    ស្ងួនស្នេហាមិត្តកល្យាណ
ជ្រៀងជ្រែបែរបៀតបាន    បៀតទៅទៀបចូលសន្និយា ។
អ្នកអើយប្អូនក្តៅក្តាត់    ថ្លើមប្រមាត់ឈឺធ្លលផ្សា
ដូចអ្នកយកខាន់ថ្លា    កាប់កាត់ប្អូនអស់ពុងពោះ ។
ចចកញីសន្លប់    ញ័រចំប្រប់សូន្យសុងសោះ
ដួលដេកនៅទីនោះ    លុះព្រលប់ចូលសន្និយា ។
សន្សើមធ្លាក់ចុះត្រង់    ជ្រាបជោកអង្គសព្វរោមា
ត្រជាក់អស់អង្គា    ភ្ញាក់ឡើងខ្ទួញសែនសល់ខ្នាត ។
ខ្ទួញតាំងពីព្រលប់    លុះចួបចប់ចូលអធ្រាត្រ
តារារះព្រោងព្រាត    ភ្លឺត្រចះពេញមេឃា ។
ចចកមៀងមើលផ្កាយ    ពុំសប្បាយថែមទុក្ខា
ថាឱផ្កាយនេះណា    ជាបរិវារអ្នកប្រុសគន់ ។
ប្អូនឃើញតែបរិវារ    បាត់សង្សារប្រុសល្ហសល្ងន់
អ្នកអើយប្អូនគយគន់    រកមៀងមើលមិនឃើញអ្នក ។
ចចកខ្ទួញទល់ទុក្ខ    គ្មានសាន្តសុខអួលអន់អាក់
លុះព្រឹកព្រាងស្វាងជាក់    ទៀងខ្ទួញទៀតសព្វវេលា ។
មួយថ្ងៃខ្ទួញបីដង    រឹងរឹតរងទុក្ខវេទនា
មួយយប់ខ្ទួញបីគ្រា    ជានិរន្តរ៍តរៀងទៅ ។
ពុំផឹកពុំបរិភោគ    ស្គមះដោដោកជោកជាំនៅ
កម្លាំងថយតិចទៅ    ខ្សោយទាបទន់ពន់ប្រមាណ ។

ដើរដួលទាំងជំហរ    នឹងទ្រាំឈរដេកពុំបាន
ក្សិណក្ស័យចាកចោលឋាន    ទាំងទម្ងន់ពោរពេញពោះ ។
ដំណើរចចកញី    ក្ស័យជីវីក្នុងគ្រានោះ
ឈប់ស្លេះនៅនេះចុះ    នឹងនិទានឯសុរិយា ។
រុងរឿងរិទ្ធីរង្សី    ស្វាងរស្មីភ្លឺលោភា
ជួបជួនប្អូនមាសា    មានពពកមកបាំងបិទ ។
ចាំងថែងសែងសុរិយ៍    អំប្បរស្មីជុំជុកជិត
បាត់វង់ព្រះអាទិត្យ    ពេញមណ្ឌលទល់មេឃា ។
ក្សិណនោះអង្គសុរិយា    ចចកណាទ្រង់គ្រោធា
ថាហើយលើកហត្ថា    ស្ទុះក្រទាចាកពិមាន ។

នេះបទពំនោលនិទាន    ដំណើរដោយដាន    ឯអង្គចចកសុរិយា ។
គ្រេវគ្រោធលោលោតស្ទុះស្ទា    តប់ទះហត្ថា    ក្រឡេកក្រឡៅប្រឹងប្រាណ ។
ថាយើនរណាហៅហាន    បាំងមុខអញបាន    ទទឹងទទែងមីរមក ។
មើលជាក់ថាយើពពក    ហ៊ានដាសពាសមក    តបតតប៉ះនឹងអញ ។
អើយើងមិនញ៉មចុះចាញ់    តយុទ្ធវិលវិញ    ឱ្យដឹងតេជដៃឥឡូវ ។
សុរិយាប្រឹងថែងចាំងទៅ    ពពកនឹងនៅ    ពុំមានកគ្រើកទៅណា ។
បាំងបិទជុំជិតសុរិយា    រឹងគ្រេវគ្រោធា    ថាអះអង្គអញសព្វថ្ងៃ ។
មិនមាននរណាមួយគ្រែ    ផ្ទឹមស្មើតេជដៃ    ប្រឡូងអំណាចខះខែង ។
មានតែអង្គអញឯកឯង    ជាធំចិញ្ចែង    ចិញ្ចាចឥតគូផ្ទឹមបាន ។
ឥឡូវពពកសាមាន្យ    បាំងសែងសូរ្យធាន    ជុំជិតងងឹតមេឃា ។
អះអញលែងជាតិសុរិយា    ហើយសូមប្រាថ្នា    កើតជាពពកនុតនាប់ ។
ដេរដាសពេញពាសខ្នាន់ខ្នាប់    សុរិយាអន់អាប់    ងងឹតងងល់ណាស់ណា ។

ពពកចចកកាឡា អាឯងមហិមា ស្រួលសើចសំណើចក្អាកក្អាយ ។
ថាអើនេះហៅសប្បាយ លើសលែងសព្វសាយ ស័ក្តិសិទ្ធិរឹងរិទ្ធិចេស្តា ។
អង្គអញលើសលែងលោកា ម្ល៉េះគ្មាននរណា ជាគូតតបរឿងរិទ្ធិ ។
អញបាំងសូរ្យសែងព្រះអាទិត្យ ដេរដាសងងឹត គ្មានរិទ្ធិស្មើអញឡើយណា ។
កាលនោះរដូវវស្សា មានព្យុះព្យោមា សន្ធឹកសន្ធាប់ខ្លាំងក្រៃ ។
បក់បោករលកជលស័យ បាក់មែកឈើព្រៃ រលំរលើងត្រៀបត្រា ។
ផាត់ផាយផុយផង់ពសុធា ផ្សែងផ្សព្វមហិមា ដង្គោលដង្គំមីរមក ។
បក់ដល់សុរិយាពពក ផាត់ផាយបាចបោក បាត់បង់ពុំគង់ប៉ុនល្អង ។
សុរិយាពពកនោះហោង ក្រោធក្រៃកន្លង ថាយើអង្គអញសព្វថ្ងៃ ។
មិនមាននរណាតដៃ ឥឡូវនេះក្រៃ មានខ្យល់ដ៏ខ្លាំងបក់ផាត់ ។
កើតជាពពកខ្សោយក្តាត់ អញចង់គិតកាត់ ជាតិជាពពកចោលចេញ ។
ប្រាថ្នាកើតជាខ្យល់វិញ ខ្យល់នេះគ្មានចាញ់ គ្មានខ្លាចអំណាចនរណា ។
កាលនោះពពកសុរិយា តាំងចិត្តប្រាថ្នា កើតជាវាយោផាត់ផាយ ។
ផាត់ផង់ធូលីខ្ទាត់ខ្ទាយ ព្រឹក្សាអន្តរាយ រលើងរលំគ្មានសល់ ។
ញាប់ញ័ររប្រឹថពីមណ្ឌល បោកបក់ទៅដល់ ដម្បូកធំស្កូកខ្ពស់ខ្ពង់ ។
ខ្យល់បក់ឆាបឆក់ត្រូវត្រង់ ដម្បូកនៅគង់ ជំហរជំហើងទប់ទល់ ។
នៅនឹងបីទ្រមឹងដូចដល់ ឥតមានអំពល់ កក្រើករំពើកឡើយណា ។
វាយោពពកគិតថា យើមាននរណា មកទល់អង្គអញជាខ្យល់ ។
អញបក់ព្រឹក្សព្រៃគ្មានសល់ ប្រឹថពីមណ្ឌល ញាប់ញ័ររន្ធត់ណាស់ណា
ទោះទឹកសមុទ្រគង្គា អញបក់បែកជា រលករលាមគ្មានសល់ ។
កាលនោះវាយោគិតឆ្ងល់ ក្នុងចិត្តខ្វាយខ្វល់ ថាអះដម្បូកស្កូកស្កឹង ។
ជំហាមគ្រមាមបីទ្រមឹង ទ្រមឹកស្កឹកស្កឹង រិទ្ធិរឹងមិនចាញ់នរណា ។
ឈ្មោះអញជាមហាវាតា ថ្មោះអញប្រាថ្នា កើតជាដម្បូកវិញចុះ ។
វាយោពពកគិតថ្មោះ លែងជាតិខ្យល់នោះ កើតជាដម្បូកស្កូកស្កឹង ។
ព្រងើយទ្រមើយទ្រមឹង ខ្យល់បក់ទៅនឹង មិនមានកម្រើកដល់តិច ។
ទោះបីខ្យល់ព្យុះម្តេចៗ បក់បោកខ្លាំងតិច ដម្បូកក៏នៅនឹងថ្កល់ ។
ដម្បូកចចកឥតឆ្ងល់ ថានេះត្រូវកល់ ចិត្តអញប្រាថ្នាមួនមាំ ។
ខ្យល់ព្យុះបក់ចុះគគ្រាំ ភ្លៀងឱរជោកជាំ អញទ្រាំអញទ្រទ្រង់បាន ។
កាលនោះមានសត្វតិរច្ឆាន ក្តាន់គ្រោសមួយមាន ហ្វូងក្តាន់ដើរតាមត្រៀបត្រា ។
ក្តាន់ដល់ដម្បូកនោះណា ចូលលិទ្ធភោក្តា ខ្លះវិធខ្លះជល់នោមជុះ ។
ខ្លះកាយរលាយរលុះ ដម្បូកធំនោះ ពុំអាចទ្រាំទ្រនៅបាន ។
ដីជ្រាយធ្លុះធ្លាយចេញថ្កាន ក្តាន់លេងជាលាន រលំដម្បូកនោះទៅ ។
ចចកដម្បូកនោះកូវ ខេខឹងក្រញូវ ក្រញែងអង្រួនសិរិសា ។
ដំបូកចចកគិតថា អញចង់ប្រាថ្នា ទៅកើតជាក្តាន់នោះវិញ ។
គិតហើយប្រែប្រាណចាកចេញ ពីដម្បូកមិញ ទៅកើតជាក្តាន់ដូចចិត្ត ។
ក្តាន់ដើររកស៊ីឆ្ងាយជិត ឥតមានភ័យភិត ក្នុងចិត្តត្រេកអរគិតថា ។
អញបានដូចចិត្តប្រាថ្នា ម្ល៉េះគ្មាននរណា ជាពីរនឹងអញទៀតទេ ។
ប្រទះក្តាន់គ្រោសនៅឯ ព្រៃជល់ទាល់តែ ចាលចាញ់រត់ខ្ចាញ់ចូលព្រៃ ។
ដំណើរក្តាន់គ្រោសនោះនៃ ឈប់ស្លេះវិលវ័យ ពុំមាននិទានឡើយណា ។

នេះនឹងប្រែបទ កាកគតិកំណត់ កំណាព្យចរចា
គិរកាលនោះមាន ព្រានព្រៃមួយណា ត្រាច់ត្រង់យាត្រា
រុករកបរបាញ់ ។
រូបរាងកំប៉េះ កំប៉ោងក្រញេស ក្រញិញក្រញាញ់
ក្រញូវក្រញើត ភ្នែកស្លើតសក់ប្រាញ់ ក្ដួចចាកកណ្តាញ
កណ្ដួបពកពាស ។

ព្រានដើរតត្រុក ព្រៃស្បាតរានរុក រកបាញ់រមាស
រមាំងប្រើសក្តាន់ កាប់កាន់ចេញពាស រកស៊ីដេរដាស
ក្រហមទាំងព្រៃ ។

រឺក្តាន់ដម្បូក រូបរាងធំស្ពូក ការហ្វូងរំពៃ
មានក្តាន់ឡើងក ចូលមករឺចវៃ ក្តាន់ដេញភិតភ័យ
ចូលជិតពុំបាន ។

រឺងព្រានព្រៃ ឃើញក្តាន់ធំក្រៃ អាពន់ប្រមាណ
ដំឡើងស្មាក្រឹត ក្រអឹតប្រុងប្រាណ លុតជង្ឃឈរឈាន
ដើរទាតចទៅ ។

លូនវារចូលជិត ភ្នែកម្ខាងព្រានបិទ ម្ខាងបើកក្រឡៅ
ក្រឡេកមិចមៀវ ស្រងៀវសំដៅ សម្រុកត្រង់ទៅ
លោះកៃស្នាភ្លាត់ ។

ត្រូវត្រង់ជាន់ឡើង ក្តាន់ដួលបះជើង ស្ទុះក្រោកឡើងថ្ងាត់
ឈើឆៀបផ្សាយផ្សា ឱរ៉ាក្តៅក្តាត់ ជ័រឆក់វាកាត់
ថ្លើមធ្លុះធ្លាយចេញ ។

ឈាមហូរច្រាស់ច្រាល ទុំទែងរន្ធាល ជោរជន់ពាសពេញ
ប្រឹងប្រែបែរបោល ដួលថ្លោលចុះវិញ ដង្ហើមប្រដេញ
ញាក់ញ័រអង្គា ។

ក្តាន់គិតរំពឹង ថាអញនេះនឹង ក្ស័យចោលរូបា
បើអញនឹងក្ស័យ ប្រល័យជន្មា សូមចាប់ជាតិជា
បន្លោះស្នាវិញ ។

ក្តាន់គិតតែម៉្លោះ ក្សិណក្ស័យសូន្យសោះ ក្រឡាប់ជាតិចេញ
ពីក្តាន់ចចក ផ្លោះផ្លកវិលវិញ វិលវឹងមកមិញ
កើតជាព្រ័ត្រស្នា ។

វឹងព្រានព្រៃ ឃើញក្តាន់ក្សិណក្ស័យ ព្រានចូលម៉្មីម្មា
ពន្លះយកសាច់ សម្រេចភោជនា ឆ្អឹងឆ្អែងរលា
ក្បាលព្រានចោលចេញ ។

រួចហើយព្រានទៅ ផ្ទះទីលំនៅ ព្រានដូចដើមវិញ
មានកាលមួយថ្ងៃ ព្រានព្រៃចរចេញ ទៅរកបរបាញ់
សត្វដូចសព្វគ្រា ។

ពុំបានសត្វសោះ វិលមកពីនោះ ព្រានគន់គិតថា
អញដើរចរចេញ រកបាញ់ម្រឹគា សព្វថ្ងៃហាក់ជា
មានជ័យមានលាភ ។

អះឱអញស្តាយ កាលអញស៊ីបាយ ភ្លេចថ្វាយបាយាប
ហេតុនោះអញស្វេង វាឆ្អែងឥតលាភ ល្ងើយចុះបាយាប
ថ្ងៃក្រោយសឹមថ្វាយ ។

ហើយទើបព្រានព្រៃ ឆៀងភ្នែករំពៃ ព្រឹក្សាទាំងឡាយ
មានមែកសាខា បុប្ផារីករាយ ភ្ញួកនឹកសប្បាយ
ក្នុងចិត្តគិតថា ។

ឱអស់ផ្កាផង ក្រអូបកន្លង សប្បាយណាស់ណា
អញចង់ច្រៀងជ្រង បានម្តងទៅរ៉ា ហើយព្រានច្រៀងថា
ទំនុកស្និទ្ធស្នេហ៍ ។

ជ្រងអើយនាងជ្រង បងចេញបាញ់ម្តង ត្រកាលជាងគេ
វាឆ្អែងអប្រិយ បានអ្វីផ្ញើមេ វិលវិញទទេ
លិទ្ធផេះជើងក្រាន ។

ស្រែកច្រៀងបណ្តើរ វេក្បាលងេងើ រមិលខ្លួនប្រាណ
មុខស្ងួញមាត់ស្មេញ សម្មេញដូចចាន ព្រានច្រៀងកំសាន្ត
ដើរដោយមាគ៌ា ។

លុះបានដល់ម្លប់ ជ្រៃមួយចូលឈប់ ចូលចតនិទ្រា
នៅក្រោមម្លប់ជ្រៃ ព្រានព្រៃផ្អែកស្មា ប្របគល់ព្រឹក្សា
ដេកលង់លក់ទៅ ។

មែនមានចចក កំព្រយកំព្រក កំព្រឹងហ្មងសៅ
ចេញពីព្រឹក្សា ម្ទីម្មាចូលទៅ ត្រង់ព្រានដេកនៅ
ក្រោមម្លប់ជ្រៃនោះ ។

ចចកថាព្រាន វាបាញ់មិនបាន សត្វមួយដល់សោះ
អញចាំភោគ្គា ដោយសារព្រាននោះ ថ្ងៃនេះឆ្អែងសោះ
គ្មានអ្វីភោគ្គា ។

ចចកមើលទៅ ឃើញស្មាផ្អែកនៅ គល់ជ្រៃសាខា
ចចកថាឱ លាភោលាភា អញទៅទំពា
បន្លោះស្មានោះ ។

អង្កៀមស៊ីលេង កុំឱ្យវាឆ្អែង វាបង់ជើងសោះ
ចចកទំពា ព្រ័ត្រស្មាក្រៀមក្រោះ ទាល់ជ្រាយដាច់ស្មោះ
ស៊ីជាភោជនា ។

ឯក្តាន់ចំនោះ ប្រាជ្ញាចំពោះ កើតជាព្រ័ត្រស្មា
លុះដល់ចចក កំព្រកមោហា ទំពាព្រ័ត្រស្មា
ដាច់ទៅដូច្នោះ ។

រឹងខឹងគ្នាន់ក្នាញ់ គិតថាអង្គអញ កើតជាបន្លោះ
ស្មានេះមានរិទ្ធិ ស័ក្តិសិទ្ធិចំពោះ ឥតគេស្មើស្មោះ
ផ្ទឹមនឹងអញបាន ។

ឥឡូវចចក នេះតើវាមក ពីណាហៅហ៊ាន
ចូលមកទំពា ព្រ័ត្រស្មាដាច់បាន ចចកនេះមាន
អំណាចជានា ។

បើច្នោះគួរអញ ប្រាជ្ញាវិលវិញ យោនយកជាតិជា
ចចកទើបបាន មែនមានឫទ្ធា គិតស្រេចការឡា
ក្រឡាប់ជាតិទៅ ។

កើតជាចចក កំព្រយកំព្រក កំព្រើលហ្មងសៅ
ដូចដើមដែលវិញ តឿទេញទាបទៅ ព្រោះលោភកំឡៅ
កម្លាំងមោហា ។

លោភលន់លើសលែង ហេតុកម្មនោះឯង នាំឱ្យប្រាជ្ញា
កើតជាចចក កំព្រកនោះណា ឥតគេស្នេហា
ជាមិត្តនិត្យនៅ ។

ហេតុនោះពាក្យព្រេង ព្រឹទ្ធប្រាជ្ញទុកតែង ទូន្មានកូនចៅ
ឱ្យប្រែលះលោភ ចេញចាកចោលទៅ កូនអើយនេះហៅ
គំនិតឆ្កែតឿ ។

ទុកជាច្បាប់ ទៅមុខគ្រាន់គ្រាប់ គ្រាន់ត្រង់កុំធ្វើ
កុំឱ្យចូលចិត្ត គំនិតឆ្កែតឿ គួរចាំគួរជឿ
គួរចៀសឱ្យឆ្ងាយ ។

កុំត្រាបចចក មោហាកំព្រក កំព្រើលអន្តរាយ
លោភក្រៅគន្លង អ្នកផងទាំងឡាយ លោភលុះអន្តរាយ
ជាតិជួរអប្រិយ ។

នេះបទព្រហ្មគីតិ	ចប់ជុំជិតជូនសេចក្ដី
ល្បិចល្បើកលើកជាថ្មី	ពីដំណើរសត្វចចក ។
ថែងចង់គ្រប់និទាន	ពីបុរាណមានរឿងមក
និយាយរាយរាប់រក	ជាតំណតទៅមុខ ។
លើកគ្រាន់មើលកំសាន្ត	គ្រាន់នឹងបានកែអផ្សុក
ជាកេរ្តិ៍ទៅមុខ	មានប្រការដូច្នេះស្រាប់ ។
ព្រះពុទ្ធ [១] សករាជគ្រាន់	គ្រប់ពីរពាន់បួនរយរាប់
វស្សាប្លាយឯកស័ប្ត	ខែកន្លងដប់មាសា ។
ថ្ងៃបានម្ភៃប្រាំ	ក៏ក្នុងឆ្នាំចឆសកា
ហេមន្តរដូវជា	ខែផល្គុនខាងឯខ្នើត ។
នាថ្ងៃព្រហស្បតិ៍	វេលាទីដប់ពីរកើត
ពាក្យពេចន៍ពាលពុំឆើត	ខុសខាតជួនផ្ទួនមិនសម ។
នាមខ្ញុំឈ្មោះសោកសឹង	អ្នកផងដឹងមិនច្រឡំ
អក្សរតួមចំ	ជើងបុកក្រោមដាក់កមុខ ។
ហើយតួសលើពីរ [២] ផង	តាមទំនងអ្នកប្រាជ្ញទុក
ឱ្យរៀនជាទំនុក	ចិត្តសំគាល់តួអក្ខរា ។
បើលោកណាមើលមៀង	កុំក្អួនដៀងដៀលនិន្ទា
ឆ្គាំឆ្គងពាក្យត្រង់ណា	ជួយតម្រង់ផងឱ្យទាន ។
សុរេចបទបរិយាយ	ជានិយាយពីបុរាណ
រៀងមកមាននិទាន	ប្រការដូច្នេះឯងហោង ។

(១) ព.ស ២៤១៧ គ.ស ១៨៧៤